# ដល់ពេល យើងត្រូវនាំគ្នាគាំទ្រផលិតផលក្នុងស្រុក!

នៅខែមាសទី១ ឆ្នាំ២០២២ អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) បានចេញផ្សាយរបាយការណ៍មួយ ដោយទាញសញ្ញាព្រួយបារម្ភថាប្រទេសនានានៅលើពិភពលោកនឹងត្រូវចំណាយប្រាក់ប្រមាណជា ១.៨ពាន់លានដុល្លារសម្រាប់ការនាំចូលស្បៀងអាហារនៅឆ្នាំនេះ។ ចំនួនទឹកប្រាក់ខ្ពស់ជាងមុនក៏ពិតមែន តែបរិមាណស្បៀងអាហារ ជាពិសេសផលិតផលកសិកម្ម រឹតតែមានតម្លៃថ្លៃ។

ក្នុងរបាយការណ៍នោះ ក៏បានពន្យល់ដែរថា ដោយសារតែតម្លៃកាន់តែកើនឡើងខ្ពស់ ចំនួនទឹកប្រាក់ប្រមាណ២ពាន់លានដុល្លារនៃចំនួន៥១ពាន់លានដុល្លារបន្ថែមទៀត នឹងត្រូវចំណាយទូទាំងពិភពលោកលើការនាំចូលស្បៀងអាហារនៅឆ្នាំនេះ។ **បើតាមកំណត់ត្រាពិភពលោកដដែលនោះ ប្រទេសមួយចំនួននឹងពុំមានលទ្ធភាពដើម្បីចំណាយទៅលើថ្លៃនាំចូលស្បៀងអាហារនោះទេ។**

ស្តុកស្រូវសាលីពិភពលោកត្រូវបានកំណត់ថានឹងកើនឡើង «តិចតួច» នៅឆ្នាំ២០២២ ដែលភាគច្រើនដោយសារតែការរំពឹងទុកនៃទុនបម្រុងធំជាងនៅក្នុងប្រទេសចិន រុស្ស៊ី និងអ៊ុយក្រែន។ ការប្រមូលផលពោតពិភពលោក និងតម្រូវការទំនងជានឹងឡើងដល់កម្រិតខ្ពស់ថ្មីមួយ ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងផលិតកម្មអេតាណុលកាន់តែច្រើននៅក្នុងប្រទេសប្រេស៊ីល និងសហរដ្ឋអាមេរិក ក៏ដូចជាការផលិតម្សៅឧស្សាហកម្មនៅក្នុងប្រទេសចិនផងដែរ។

នៅក្នុងរបាយការណ៍នោះ ក៏បានបង្ហាញថា ផលិតកម្មវារីវប្បកម្មសកល ត្រូវបានព្យាករណ៍ថានឹងកើនឡើង២.៩ភាគរយ ខណៈដែលការនេសាទពាណិជ្ជកម្មទំនងជានឹងពង្រីកបានត្រឹមតែ០.២ភាគរយប៉ុណ្ណោះ។ ទន្ទឹមនឹងនេះប្រាក់ចំណូលនៃការនាំចេញសរុប ពីជលផល និងវារីវប្បកម្មត្រូវបានរំពឹងថានឹងកើនឡើង២.៨ភាគរយ បើទោះបីជាបរិមាណនឹងធ្លាក់ចុះត្រឹម ១.៩ភាគរយក៏ដោយ។

ក្នុងបរិបទប្រទេសកម្ពុជា យោងតាមសារាចរណ៍ណែនាំ រាជរដ្ឋាភិបាលកម្ពុជា លេខ ០៤សរណន ស្តីពីការរៀបចំសេចក្តីព្រៀងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ បានបញ្ជាក់ថា អតិផរណានឹងថមថយមកវិញនៅរង្វង់២.៥% នៅឆ្នាំ២០២៣ ដោយសារតែការរំពឹងទុកនូវការវិលត្រឡប់ទៅរកប្រក្រតីភាពវិញនៃថ្លៃប្រេង និងទំនិញផ្សេងៗទៀត ក៏ដូចជាសកម្មភាពសេដ្ឋកិច្ច។

**កិច្ចខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់ផលិតផលក្នុងស្រុកឈានទៅកាត់បន្ថយអតិផរណាស្បៀងអាហារ**

ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារអាហារ ដែលមាន១១ ជំពូក និង៤៣ មាត្រា ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២។ ច្បាប់នេះកំណត់អំពីក្របខណ្ឌនិងយន្តការសម្រាប់គ្រប់គ្រង ធានាសុវត្ថិភាព គុណភាព អនាម័យ និងភាពស្របច្បាប់នៃម្ហូបអាហារ ក្នុងគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ ដើម្បីផ្តល់ការការពារសុខភាព និងសុវត្ថិភាពម្ហូបអាហារ សម្រាប់អ្នកប្រើប្រាស់ និងធានាឱ្យមានការធ្វើពាណិជ្ជកម្មម្ហូបអាហារប្រកបដោយភាពស្មោះត្រង់។

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងគុណភាព និងសុវត្ថិភាពម្ហូបអាហារ ដែលគ្របដណ្តប់គ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ និងលើអាជីវកម្មម្ហូបអាហារនៅព្រះរាជាណាចក្រកម្ពុជា សំដៅធានាកម្រិតនៃការការពារអាយុជីវិត និងសុខភាពប្រជាពលរដ្ឋ គ្រប់គ្រងហានិភ័យម្ហូបអាហារដែលចរាចរលើទីផ្សារ និងម្ហូបអាហារនាំចូល និងធានាប្រសិទ្ធភាពនៃការការពារផលប្រយោជន៍អ្នកប្រើប្រាស់។

ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ រៀបចំឡើងដើម្បីឆ្លើយតបតាមតម្រូវការនៃពាណិជ្ជកម្មក្នុងស្រុក និងអន្តរជាតិ ការពារសុខុមាលភាពប្រជាពលរដ្ឋ និងទំនិញមានគុណភាព ព្រមទាំងសុវត្ថិភាពល្អ ឱ្យអ្នកប្រើប្រាស់នៅក្នុងស្រុកកាន់តែមានទំនុកចិត្ត និងមកគាំទ្រផលិតផលនៅក្នុងស្រុកកាន់តែច្រើន ជំនួសឱ្យការទិញ និងបរិភោគស្បៀងអាហារដែលនាំចូលពីប្រទេសក្បែរខាង។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធដទៃទៀត ក៏ជំរុញផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ផលិតផលក្នុងស្រុក ដើម្បីចូលរួមលើកកម្ពស់ផលិតផលជាតិ បង្កើតការងារ និងផ្តល់ប្រាក់ចំណូលដល់ប្រជាពលរដ្ឋ ។

ដើម្បីជំរុញសកម្មភាពពាណិជ្ជកម្មសេរី បង្កើតឱកាសទីផ្សារ និងសក្តានុពលវិនិយោគ ក្រសួងពាណិជ្ជកម្ម ក៏តែងតែរៀបចំព្រឹត្តិការណ៍ពិព័រណ៍ផលិតផលក្នុងស្រុកជាបន្តបន្ទាប់។ កិច្ចខិតខំប្រឹងប្រែងនេះ ជាលទ្ធផលឃើញថា និន្នាការគាំទ្រផលិតផលក្នុងស្រុកមានការកើនឡើងជាបន្តបន្ទាប់ ដែលបានចូលរួមលើកស្ទួយជីវភាពរបស់សហគមន៍អ្នកផលិត និងកែច្នៃឱ្យកាន់តែប្រសើរឡើង ។

**ហេតុអ្វីយើងគួរនាំគ្នា គាំទ្រផលិតផលក្នុងស្រុក?**

តើអ្នកមានដឹងទេ? នៅក្នុងមួយឆ្នាំៗ កម្ពុជានាំចូលផលិតផលអាហារកែច្នៃ បន្លែ ផ្លែឈើ ត្រីសាច់ផ្សេងៗ គឺមានតម្លៃមិនក្រោមពី៧ទៅ៨ពាន់លានដុល្លារទេ។ គ្រាន់តែច្រកអន្តរជាតិប៉ោយប៉ែត ដែលជាច្រកជាមួយនឹងប្រទេសថៃ មានការដឹកជញ្ជូននូវផលិតផលមីកញ្ចប់ ក្នុងតម្លៃគិតជាទឹកប្រាក់រហូតដល់ ១០០ លានដុល្លារអាមេរិក។ ទំហំទឹកប្រាក់នេះ នៅមិនទាន់បានបូកបញ្ចូល នៅតាមច្រកទ្វារអន្តរជាតិសំខាន់ៗផ្សេងទៀត ដែលនាំចូលទំនិញជាស្បៀងអាហារសំខាន់ៗទៀតផង ដូចជាបន្លែ ត្រី សាច់ គ្រាប់ធញ្ញជាតិ ជាដើម។

បើយើងក្រឡេកមើលតួលេខខាងលើនេះ គឺមិនមែនជាចំនួនតិចនោះទេ។ យ៉ាងណាមិញប្រសិនបើយើងទាំងអស់គ្នាងាកមកប្រើប្រាស់ផលិតផលក្នុងស្រុក យើងនឹងទទួលបានផលប្រយោជន៍ជាច្រើន។ ចំណុចសំខាន់ទី១ **គឺបង្កើតមុខរបរថ្មីដល់អ្នកអាជីវកម្ម ទី២គឺផ្តល់ការងារធ្វើដល់ប្រជាជនផ្តល់ឱកាសការងារដល់ប្រជាជនក្នុងតំបន់ ទី៣ គឺចំណេញការដឹកជញ្ជូនកាត់បន្ថយចំណាយលើថ្លៃដឹកជញ្ជូននិងទី៤គឺផ្តល់ផលចំណេញដល់សេដ្ឋកិច្ចជាតិ ដោយសារតែមានចរន្តសេដ្ឋកិច្ចវិលជុំ។**

យើងដឹងថា ការងាកមកគាំទ្រនូវផលិតផលក្នុងស្រុក មិនមែនជារឿងដែលងាយស្រួល ហើយអាចកើតឡើងបានភ្លាមៗនោះទេ នេះក៏ដោយសារតែសមត្ថភាពផលិតនៅក្នុងស្រុកនៅមានកម្រិតនៅឡើយ ហើយការកែច្នៃនៅតែមានចន្លោះដែលត្រូវការវិនិយោគនិងកែកុនបន្ថែម។ ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំមានសុទិដ្ឋិនិយមថា ម្ចាស់អាជីវកម្មឬអ្នកផលិតនឹងខិតខំកែច្នៃផលិតផលរបស់ខ្លួនឲ្យសមស្របតាមតម្រូវការទីផ្សារក្នុងស្រុក ដោយមានទាំងគុណភាព អនាម័យ តម្លៃសមរម្យ និងសេវាកម្មល្អ ដើម្បីទទួលបានការគាំទ្រពីអ្នកប្រើប្រាស់កាន់តែច្រើនពីទីផ្សារក្នុងស្រុក និងអន្តរជាតិ។

ការអនុវត្តកសិកម្មតាមគោលការណ៍ក្សេត្របរិស្ថាន គឺជាការធ្វើកសិកម្មដែលជា «មជ្ឈមណ្ឌលនៃការផលិតស្បៀងអាហារ ដែលប្រើប្រាស់នូវសេវាកម្មនិងផលិតផលរបស់ធម្មជាតិដែលមានជាច្រើន ដោយមិនមានការបំផ្លាញនូវធនធានទាំងនោះ»។ ហើយវាក៏ជាការផ្សារភ្ជាប់ទៅអេកូឡូស៊ី សេដ្ឋកិច្ចសង្គម និងវប្បធម៌ដើម្បីធ្វើអោយផលិតផលកសិកម្ម សហគមន៍ដែលធ្វើកសិកម្ម និងសុខភាពបរិស្ថានមាននិរន្តរភាព។

ថ្វីត្បិតតែការប្រើប្រាស់សារធាតុគីមី វាអាចនឹងផ្តល់ទិន្នផល និងផលិតផលបានលឿនបន្តិចមែន ប៉ុន្តែ វាក៏បានផ្តល់ផលប៉ះពាល់អវិជ្ជមានជាច្រើនត្រលប់មកវិញដូចជាៈ ការប៉ះពាល់ដល់សុខភាព បរិស្ថាន សេដ្ឋកិច្ចគ្រួសារ និងសង្គមផងដែរ។

ការថយចុះនូវជីវជាតិដី តាមរយៈការប្រើប្រាស់សារធាតុគីមីលើសកំណត់ បានបំផ្លាញសត្វល្អិតមានប្រយោជន៍ ធ្វើឱ្យដីសឹករិចរិល និងអស់ជីវជាតិ ដែលធ្វើឱ្យផលិតភាពមានការធ្លាក់ចុះ។ ម្យ៉ាងវិញទៀត ការអនុវត្តកសិកម្មតាមគោលការណ៍ក្សេត្របរិស្ថាន ក៏អាចជួយធ្វើអោយប្រសើរឡើងនូវគុណភាព និងជីវជាតិដី តាមរយៈការប្រើប្រាស់ជីកំប៉ុស្តិ៍ ជីស្រស់ ការដាំដំណាំឆ្លាស់ និងដំណាំចម្រុះ ជាពិសេស បង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងអធិបតេយ្យភាពស្បៀង (ម្ចាស់សិទ្ធិនៃការផលិត) លើកកម្ពស់ឱ្យមានការផលិត និងទីផ្សារនៅក្នុងស្រុក។ លើសពីនេះទៀត វាថែមទាំងផ្តល់ផលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់មិនថាទាំងសម្រាប់អ្នកផលិត (កសិករ) និងអ្នកប្រើប្រាស់ ហើយវានឹងក្លាយជាកត្តាមួយដ៏សំខាន់ក្នុងការលុបបំបាត់ការពឹងផ្អែកទាំងស្រុងលើជាតុចូលកសិកម្ម (ជី ថ្នាំពុលថ្នាំសម្លាប់សត្វល្អិត) ជាដើម។

តាមរយៈការចុះអង្កេតផ្ទាល់ និងសិក្សាស្រាវជ្រាវរបស់អង្គការអាក់សិនអេតកម្ពុជានៅតាមបណ្តាសហគមន៍ដែលបាន អនុវត្តសកម្មភាពតាមគោលការណ៍នេះកន្លងមក យើងសង្កេតឃើញថាកសិករ(អ្នកផលិត) មានការផ្លាស់ប្តូរប្រសើរជាងមុនទាំងឥរិយាបថ ចំណេះដឹង និងជីវភាព។ យ៉ាងណាមិញ ការផ្លាស់ប្តូរនេះអាចកើតឡើងបាន ដោយសារតែកសិករ សហគមន៍ មានការយល់ដឹងច្រើនជាងមុនទាក់ទឹងផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់សារជាតុគីមីសម្រាប់ការងារកសិកម្មរបស់ពួកគាត់។ ហេតុនេះហើយ ទើបពួកគាត់បានបង្វែរ ឬព្យាយាមឈប់ប្រើប្រាស់សារជាតុគីមីដែលនាំចូលមកពីខាងក្រៅ មកប្រើប្រាស់វិញនូវធនធានដែលមានស្រាប់ក្នុងតំបន់ ដែលអាចប្រើប្រាស់ និងកែច្នៃបាន ហើយចំណាយដើមទុនតិចទៀត( ពូជក្នុងស្រុក ការផលិតជីកំប៉ុស្តទឹក និងគោក ជីបំប៉ន និងថ្នាំពុលបណ្តេញសត្វធម្មជាតិ ផលិតចំណីជាដើម)។

តាមពិតអ្វីដែលយើងមិនគួរមើលរំលង ការអនុវត្តកសិកម្មតាមគោលការណ៍ក្សេត្របរិស្ថាន ពិតជាសំខាន់ និងចាំបាច់ក្នុងការរួមចំណែកក្នុងការលើកស្ទួយជីវភាពសហគមន៍ ចរន្តសេដ្ឋកិច្ចសង្គម និងប្រទេសទាំងមូលផងដែរ។ លើសពីនេះទៅទៀត វាបានចូលរួមយ៉ាងសកម្មក្នុងការការពារបរិស្ថាន(សុវត្ថិភាពទាំងអ្នកផលិត អ្នកប្រើប្រាស់ និងធនធានធម្មជាតិ។ ជាពិសេស លើកស្ទួយសេដ្ឋកិច្ច ថែរក្សាសង្គម-វប្បធម៌ និងរួមចំណែកក្នុងការអនុវត្តនយោបាយរបស់ប្រទេសផងដែរ។

ដូច្នេះហើយ កាលណាប្រជាពលរដ្ឋយើងនាំគ្នាចូលរួមគាំទ្រផលិតផលនៅក្នុងស្រុក មានន័យថា យើងនាំគ្នាចូលរួមគាំទ្រ និងបង្កើតការងារបន្ថែមសម្រាប់ប្រជាជនក្នុងស្រុក គាំទ្រ និងលើកស្ទួយផលិតផលក្នុងស្រុក ជាពិសេស ធ្វើអោយប្រជាជនក្នុងតំបន់មានការងារធ្វើច្រើនជាងមុន(កាត់បន្ថយការចំណាកស្រុក) អាចបង្កើនប្រាក់ចំណូល សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ និងរួមចំណែកសាងសេដ្ឋកិច្ចប្រទេសជាតិផងដែរ។

**អត្ថបទទស្សនវិភាគនេះ ជាវិភាគទាន និងបទវិភាគ ដោយលោកស្រី យង់ វីរៈសុភមង្គល មន្ត្រីក្សេត្របរិស្ថាននៃអង្គការអាក់សិនអេតកម្ពុជា៕**